# ទីបន្ទាល់ របស់អ៊ីថាន

**ដោយ ឡារី ហិល្លី**
ផ្អែកទៅលើដំណើររឿងពិត

*« សូមស្ដាប់ សូមស្ដាប់ ។ ព្រះវិញ្ញាណបរិសុទ្ធនឹងខ្សឹបប្រាប់ ។ សូមស្ដាប់ សូមស្ដាប់សំឡេងតូចរហៀង »* ( ចម្រៀងកុមារ ១០៦ ) ។

អ៊ីថានបានអង្គុយនៅក្នុងការប្រជុំពេលវេលាចែកចាយ ហើយបានសម្លឹងមើលទៅ សាមមិត្តភក្តិដ៏ជិតស្និទ្ធរបស់គាត់ថ្លែងទីបន្ទាល់របស់ខ្លួន ។ មិត្តភក្តិរបស់គាត់ សារ៉ាកំពុងអង្គុយលើវេទិកា រង់ចាំដល់វេនរបស់នាង ។ សាមបាននិយាយអំពីគម្រោងបម្រើមួយដែលគាត់បានធ្វើ ។ គាត់បាននិយាយថា គាត់មានទីបន្ទាល់អំពីការបម្រើ ។ សារ៉ាបានថ្លែងទីបន្ទាល់របស់នាងអំពីក្រុមគ្រួសារ ។ គ្រូរបស់អ៊ីថានក៏ថ្លែងទីបន្ទាល់របស់គាត់ផងដែរ ។ គាត់បាននិយាយអំពីកិច្ចការព្រះវិហារបរិសុទ្ធ ។ ពួកគេទាំងអស់គ្នាបានថ្លែងថា សាសនាចក្រនេះពិត ។ គ្រប់គ្នាទំនងជាមាននូវទីបន្ទាល់មួយលើកលែងតែអ៊ីថានប៉ុណ្ណោះ ។

« តើខ្ញុំមានទីបន្ទាល់អំពីអ្វីខ្លះ ? » អ៊ីថានបានងឿងឆ្ងល់ ។

គាត់បានគិតពីរយៈពេលពីរបីឆ្នាំមុន នៅពេលគាត់នឹងមិត្តភក្តិរបស់គាត់បានជ្រមុជទឹក ។ គ្រូបង្រៀនថ្នាក់បឋមសិក្សារបស់គាត់ គឺបងស្រីខាលឌើរ បាននិយាយអំពីព្រះវិញ្ញាណបរិសុទ្ធ ។

« ព្រះវិញ្ញាណបរិសុទ្ធអាចធ្វើឲ្យអ្នកមានអារម្មណ៍ខ្ជួលខ្ញាញ់ក្នុងដួងចិត្តរបស់អ្នក ។ គាត់បាននិយាយថា ទ្រង់អាចជួយអ្នកដឹងពីអ្វីដែលពិត » ។ « ហើយនោះគឺជារបៀបដែលអ្នកទទួលនូវទីបន្ទាល់មួយអំពីអ្វី ដែលអ្នកជឿ » ។



*គ្រប់គ្នាទំនងជាមាននូវទីបន្ទាល់មួយលើកលែងតែអ៊ីថានប៉ុណ្ណោះ ។*

អ៊ីថានបានព្យាយាមធ្វើនូវអ្វីដែលត្រឹមត្រូវប្រយោជន៍ឲ្យគាត់ទទួលអារម្មណ៍ពីព្រះវិញ្ញាណបរិសុទ្ធ ។ គាត់បានអានព្រះគម្ពីរ ហើយអធិស្ឋាន ។ ប៉ុន្តែគាត់ពុំដែលធ្លាប់មានអារម្មណ៍ខ្ជួលខ្ញាញ់ក្នុងចិត្តដូចគេបាននិយាយឡើយ ។ តើការណ៍នេះមានន័យថា គាត់ពុំមានទីបន្ទាល់ឬ ?

សំណួរនេះបានដក់នៅក្នុងចិត្តរបស់អ៊ីថាននៅថ្ងៃបន្ទាប់នោះ ។ គាត់កំពុងគិតអំពីវានៅពេលគាត់ និងសាមលេងជិះកូនក្ដាររំអិលបន្ទាប់ពីមកពីសាលាវិញ ។ គាត់បានងឿងឆ្ងល់ពីរបៀបដែលគាត់អាចសួរសាមអំពីទីបន្ទាល់នោះ ។

ទីបំផុតអ៊ីថានបានសួរ « ហេ៎ សាម តើឯងមានការភ័យខ្លាចទេ នៅពេលឯងបានថ្លែងទីបន្ទាល់កាលពីម្សិលមិញនោះ ? »

សាមបានស្ទុះចេញពីកូនក្ដាររំអិល ហើយបានដើរទៅវាលស្មៅ ។ គាត់និយាយពេលកំពុងអង្គុយថា « អត់ខ្លាចទេ » ។ « ខ្ញុំបានចែកចាយទីបន្ទាល់របស់ខ្ញុំនៅពេលយប់ជាមួយគ្រួសារពីមុនខ្ញុំចែកចាយវានៅព្រះវិហារ » ។

អ៊ីថានបានអង្គុយជាមួយគាត់ ហើយបានដាក់កូនក្ដាររំអិលលើភ្លៅរបស់ខ្លួន ។ « ប៉ុន្តែ តើអ្នកបានដឹងថា អ្នកមានទីបន្ទាល់មួយដោយរបៀបណា ? »

« មែនហើយខ្ញុំបានអធិស្ឋាន ហើយខ្ញុំមានអារម្មណ៍ល្អពីវា » ។

អ៊ីថានបានងក់ក្បាលយឺតៗ ហើយយកដៃខ្លួនបង្វិលកង់ ។ ដោយគាត់ចង់មានអារម្មណ៍បែបនោះផងដែរ ។

នាពេលយប់នោះ ជាពេលងងឹត ហើយស្ងាត់ អ៊ីថានបានលុតជង្គង់ចុះក្បែរគ្រែរបស់ខ្លួនដើម្បីអធិស្ឋាន ។

គាត់បាននិយាយថា « ព្រះវរបិតាសួគ៌ សូមជួយទូលបង្គំឲ្យមានទីបន្ទាល់ផង ។ សូមជួយទូលបង្គំឲ្យដឹងថា សាសនាចក្រនេះពិត ។ ថាយ៉ូសែប ស្ម៊ីធ គឺជាព្យាការី ។ ហើយថាព្រះគម្ពីរមរមនពិត » ។

នៅពាក់កណ្ដាលនៃការអធិស្ឋានរបស់គាត់ អ៊ីថានបានឈប់ ។ គាត់បានគិតមួយសន្ទុះ ។ ក្រោយមកគាត់បានសួរខ្លួនឯងថា « មែនហើយ តើខ្ញុំដឹងអ្វីខ្លះហើយ ? »

ហើយក្រោយមកអារម្មណ៍ស្ងប់ស្ងាត់ សុខសាន្តបានមានលើគាត់ ។ វាមិនមែនជាអារម្មណ៍ដ៏ឆេះខ្ជួលខ្ញាញ់ឡើយ ។ ប៉ុន្តែអ៊ីថានបានដឹង *ថា* នោះគឺជាព្រះវិញ្ញាណបរិសុទ្ធ ។

មានគំនិតមួយផុសឡើងនៅក្នុងចិត្តរបស់អ៊ីថាន ៖ « ខ្ញុំដឹងថាខ្ញុំស្គាល់អារម្មណ៍នេះ » ។ ហើយនៅពេលគាត់បានគិតពីអារម្មណ៍នោះ គាត់បានដឹងថាគាត់ធ្លាប់មានអារម្មណ៍ដ៏សុខសាន្តនេះពីមុនមក ។

នៅពេលគាត់បានអានព្រះគម្ពីរមរមន វាធ្វើឲ្យគាត់មានអារម្មណ៍ល្អនិងត្រឹមត្រូវ ។ ឥឡូវគាត់បានដឹងថា អារម្មណ៍នោះគឺមកពីព្រះវិញ្ញាណបរិសុទ្ធដែលថ្លែងទីបន្ទាល់ដល់គាត់ ។ នៅពេលគាត់បានទៅព្រះវិហារ ហើយវាធ្វើឲ្យគាត់មានអារម្មណ៍ល្អ និងត្រឹមត្រូវនៅទីនោះ នោះគឺជាអារម្មណ៍នៃព្រះវិញ្ញាណបរិសុទ្ធផងដែរ ។ គាត់បានមានទីបន្ទាល់មួយរួចទៅហើយ !

គាត់មិនចាំបាច់ត្រូវដឹងគ្រប់យ៉ាងក្នុងពេលនេះឡើយ ។ ប៉ុន្តែគាត់បានដឹងថាព្រះវិញ្ញាណបរិសុទ្ធគឺពិត ហើយអាចជួយគាត់ឲ្យបន្តស្ថាបនាទីបន្ទាល់របស់គាត់ ។

អ៊ីថានបានចាប់ផ្ដើមអធិស្ឋានម្ដងទៀត ។ ប៉ុន្តែលើកនេះគឺជាពេលដើម្បីថ្លែងអំណរគុណ ។ ■

*អ្នកនិពន្ធរស់នៅរដ្ឋ យូថាហ៍ ស.រ.អា ។*

រូបគំនូរដោយ មេលីស្សា មែនវីល